**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងឧស្សាហកម្ម និង សិប្បកម្ម**
**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
លេខ: ០៤៤/០ ស.ស.រ

# សេចក្ដីសម្រេច
## ស្ដីពី ការប្រគល់ភារកិច្ចបន្ថែម

## អគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

- បានឃើញព្រះរាជក្រមលេខ ជស/រកម០៦៩៦/០៣ចុះថ្ងៃទី១៧-០៦-១៩៩៦ស្ដីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៤១អនក្រ.បកចុះថ្ងៃទី០៦-០៨-១៩៩៧ស្ដីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈនិងអនុក្រឹត្យលេខ៧១អនក្រ.បកចុះថ្ងៃទី២២-០៤-២០១១ស្ដីពីការបំពេញការងារបន្ថែមអនុក្រឹត្យលេខ៤១ អនក្រ.បក
- បានឃើញអនុក្រឹត្យលេខ៥២អនក្រ.បកចុះថ្ងៃទី១៩-១២-១៩៩៦ ស្ដីពីការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលត្រូវបានធ្វើវិសោធនកម្មដោយអនុក្រឹត្យលេខ៣៤អនក្រ.បកចុះថ្ងៃទី ១២-០៦-២០០០ និងអនុក្រឹត្យលេខ១៤ អនក្រ.បក ចុះថ្ងៃទី ២៤-០៥-២០០៤
- បានឃើញអនុក្រឹត្យលេខ៦៦៤ អនក្រ.តតចុះថ្ងៃទី ០៨-០៦-២០១២ ស្ដីពីការតែងតាំងអគ្គនាយក រ-ទ-ស-ភ
- បានឃើញអនុក្រឹត្យលេខ៨៩៩អនក្រ.តតចុះថ្ងៃទី២៧-០៧-២០១២ស្ដីពីការតែងតាំងក្រុមប្រឹក្សាភិបាលអាណត្តិទី៥
- យោងសេចក្ដីសម្រេចលេខ ០០២ស.ស.រ ចុះថ្ងៃទី ០៣-០១-២០១៣ ស្ដីពីការបែងចែកភារកិច្ចថ្នាក់ដឹកនាំ រ.ទ.ស.ភ
- យោងសេចក្ដីសម្រេចលេខ ០៦៥ ស.ស.រ ចុះថ្ងៃទី ២៧-០៨-២០១៤ ស្ដីពីការដាក់មន្ត្រីនិយោជិតអោយចូលនិវត្តន៍
- យោងតម្រូវការចាំបាច់របស់ រ.ទ.ស.ភ ។

## <u>សម្រេច</u>

**ប្រការ១**: ប្រគល់ភារកិច្ចជូនលោក **រស់ គឹមលាង** បច្ចុប្បន្នជាអគ្គនាយករងទទួលបន្ទុកហិរញ្ញកិច្ច និងផ្សារមូលប័ត្រ ឲ្យទទួលខុសត្រូវបន្ថែមជា ប្រធាននាយកដ្ឋាន គណនេយ្យ និង ហិរញ្ញវត្ថុ ។

**ប្រការ២**: រាល់ចំណាត់តាំងពីមុន ដែលមានខ្លឹមសារផ្ទុយពីសេចក្ដីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៣**: គ្រប់អគ្គនាយករង ប្រធាននាយកដ្ឋាន ការិយាល័យ អង្គភាពចំណុះរ.ទ.ស.ភ ព្រមទាំងសាមីខ្លួនត្រូវទទួលអនុវត្តនូវសេចក្ដីសម្រេចនេះឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ, ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ២០១៤
**អគ្គនាយក**

**ស៊ឹម ស៊ីថា**

<u>កន្លែងទទួល</u>
- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- មន្ត្រីត្រួតពិនិត្យរដ្ឋអម រ.ទ.ស.ភ
- គណៈកម្មាការមូលប័ត្រកម្ពុជា
- ផ្សារមូលប័ត្រកម្ពុជា "មេត្តាជ្រាប"
- ដូចក្នុងប្រការ ៣ "ដើម្បីអនុវត្ត និង មុខការ"
- ឯកសារ-កាលប្បវត្ត